01108641

F26

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2015, 15:37
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរិវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

# សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**ជនជាប់ចោទ**

ខៀវ សំផន

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**") ,

**កត់សម្គាល់**ដីកាកំណត់កាលបរិច្ឆេទសវនាការ[1]របស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខនៅថ្ងៃទី ២, ៣, ៦ និង ក្នុងករណីចាំបាច់ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៥ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5 ("ដីកាកំណត់កាលបរិច្ឆេទសវនាការ"),

**រំលឹកថា** ដីកាកំណត់កាលបរិច្ឆេទបានភ្ជាប់ជាមួយនូវកាលវិភាគបណ្តោះអាសន្នមួយ ដែលភាគីត្រូវបានស្នើឱ្យដាក់សេចក្តីសង្កេតរបស់ខ្លួន ប្រសិនបើមាន ត្រឹមថ្ងៃ សុក្រ ទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥[2],

**កត់សម្គាល់**សេចក្តីសង្កេតដាក់ដោយ នួន ជា និង ខៀវ សំផន (ជារួម "ជនជាប់ចោទ"),[3] ដែលក្នុងនោះបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យ៖ (១) ផ្តល់ពេលវេលាបន្ថែមសម្រាប់ការពិនិត្យលើសាក្សីនីមួយៗដែលបានកោះហៅ[4], (២) ចាត់ទុកពេលវេលាដែលបានផ្តល់ឱ្យនោះថាជា "ពេលវេលាសួរសំណួរសុទ្ធ" គឺថា មិនរាប់បញ្ចូលនូវពេលចំណាយលើរំខាននានា និង (៣) បញ្ឈប់នូវការអនុវត្តក្នុងការអនុញ្ញាតឱ្យសាក្សីពិនិត្យលើចម្លើយពីមុនរបស់ខ្លួន មុនពេលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ[5],

---

[1] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F24 (សំណៅដែលត្រូវបានកែប្រែ ដាក់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥) ("ដីកាកំណត់កាលបរិច្ឆេទសវនាការ")។

[2] ដីកាកំណត់កាលបរិច្ឆេទ ទំព័រ ៣ (កថាខណ្ឌទីបីដែលលើកនូវចំណុចនេះ)។

[3] សេចក្តីសង្កេតរបស់ នួន ជា ស្តីពីដីកាកំណត់កាលបរិច្ឆេទសវនាការសម្រាប់ពិនិត្យសាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5, ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F24/8 ("សេចក្តីសង្កេតរបស់ នួន ជា"); សេចក្តីសង្កេតរបស់ ខៀវ សំផន ស្តីពីដីកាកំណត់កាលបរិច្ឆេទសវនាការសម្រាប់ពិនិត្យសាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5, ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F24/9 ("សេចក្តីសង្កេតរបស់ ខៀវ សំផន")។

[4] សេចក្តីសង្កេតរបស់ នួន ជា កថាខណ្ឌ ៣ (ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលផ្តល់ពេលវេលាមួយម៉ោងបន្ថែមទៀតសម្រាប់ការពិនិត្យសាក្សីរហស្សនាម SCW-5); សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៣ (ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលផ្តល់ពេលវេលាបន្ថែមចំនួន ១៥ នាទីសម្រាប់ការពិនិត្យលើសាក្សីរហស្សនាម SCW-3, ១៥ នាទីទៀតសម្រាប់ពិនិត្យសាក្សី SCW-4, និង ៣០ នាទីសម្រាប់ពិនិត្យសាក្សីរហស្សនាម SCW-5)។

[5] សេចក្តីសង្កេតរបស់ នួន ជា កថាខណ្ឌ ២ ដល់ ៤។ សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ២ ដល់ ៥។

**កត់សម្គាល់**សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំការអនុញ្ញាតដល់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗមួយចំនួនបានចូលរួមសវនាការនេះ[6],

**ពិចារណាឃើញ**ថា ដោយហេតុថា សំណើរបស់ **នួន ជា** និង **ខៀវ សំផន** សុំបន្ថែមពេលវេលាពិនិត្យសាក្សីរហស្សនាម SCW-5 មានលក្ខណៈសមស្របដោយសារការរំពឹងទុកនូវទំហំនៃការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ ប៉ុន្តែសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលាក្នុងការពិនិត្យលើសាក្សីពីររូបដទៃទៀតនោះ ពុំមានមូលដ្ឋានគាំទ្រណាមួយដែលគួរឱ្យជឿជាក់បានទេ,

**ពិចារណាឃើញ**ថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ ត្រូវគោរពតាមការរៀបចំសវនាការនៃកិច្ចដំណើរការនីតិវិធីឱ្យមានប្រសិទ្ធិភាព, សិទ្ធិរបស់ជនជាប់ចោទ និងវិធានការការពារផ្សេងៗទៀតសម្រាប់សាក្សី[7], ហេតុនេះ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការនេះ គឺអាស្រ័យលើទីកន្លែងទំនេរដែលមាននៅក្នុងបន្ទប់សវនាការ និងពុំត្រូវបានអនុញ្ញាតឡើយ ក្នុងករណីដែលមានដីកាបង្គាប់ឱ្យមានវិធានការការពារ ទាក់ទងនឹងសាក្សីណាមួយដែលបានកោះហៅនោះ,

**ពិចារណាឃើញ**ថា ដើម្បីជួយសម្រួលដល់ការរៀបចំកិច្ចដំណើរការនីតិវិធីឱ្យមានប្រសិទ្ធិភាព និងដោះស្រាយនូវក្តីបារម្ភរបស់ជនជាប់ចោទ ទាក់ទងនឹងលទ្ធភាពនៃការកង្វះពេលវេលាដែលបានផ្តល់ឱ្យនោះ ដោយបណ្តាលមកពីការជំទាស់ និងការកាត់សំដីផ្សេងៗដែលនឹងកើតមាន[8] ហេតុនេះ វាមានលក្ខណៈសមស្របក្នុងការបង្ហាញនូវសេចក្តីណែនាំមួយចំនួនស្តីពីកិច្ចដំណើរការនៃសវនាការ,

**ពិចារណាឃើញ**ថា សាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5 គឺជាសាក្សីរបស់តុលាការ អាស្រ័យហេតុនេះ ការតាំងសំណួរ គឺពុំខុសគ្នាពីភាគីដទៃទៀតឡើយ,

**បញ្ជាក់**ថា សេចក្តីណែនាំនេះដែលបានអនុម័តដោយអង្គជំនុំជម្រះតុលាការកំពូល ពុំមានអានុភាពទៅលើទឡ្ហីករណ៍ណាមួយនៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយជនជាប់ចោទឡើយ,

---

[6] អ៊ីមែលផ្ញើពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា "កិច្ចដំណើរការនៃកិច្ចដំណើរនីតិវិធីរបស់តុលាការ" ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ម៉ោង ០៣ និង ៥០ នាទីរសៀល ដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[7] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F10/2 កថាខណ្ឌ ១៥ និង ១៧។

[8] សេចក្តីសង្កេតរបស់ នួន ជា កថាខណ្ឌ ២។ សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៤។

**អាស្រ័យហេតុនេះ:**

**សម្រេច** ផ្ដល់រយៈពេលមួយ(០១)ម៉ោងបន្ថែមទៀតឱ្យ **នួន ជា** និង សាមសិប(៣០)នាទីឱ្យ **ខៀវ សំផន** សម្រាប់ការសួរសំណួរសាក្សីរហស្សនាម SCW-5,

**ភ្ជាប់**មកជាមួយសេចក្ដីណែនាំនេះ នូវឧបសម្ព័ន្ធនៃកាលវិភាគដែលបានកែប្រែសម្រាប់សវនាការនេះ[9],

**ស្នើ**ឱ្យសហមេធាវីនាំមុខដំណាងដើមបណ្ដឹងរដ្ឋប្បវេណីជូនដំណឹងដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលតាមរយៈអ៊ីម៉េលត្រឹមថ្ងៃសុក្រ ទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ លើបញ្ហាថាតើ និងប្រសិនបើមាន ដើមបណ្ដឹងរដ្ឋប្បវេណីរូបណាខ្លះ ដែលមានបំណងចង់ចូលរួមនៅក្នុងបន្ទប់សវនានាការធំ ក្នុងអំឡុងពេលសវនាការនោះ,

**បង្គាប់**ថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពុំត្រូវផ្ដល់ឯកសារចម្លងនៃចម្លើយពីមុនរបស់សាក្សីឱ្យទៅសាក្សី មុនពេលការផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការនេះទេ,

**បង្គាប់**ថា **ភាគីត្រូវអនុវត្តតាម**សេចក្ដីណែនាំដូចខាងក្រោម ក្នុងអំឡុងពេលសវនាការ:

១. *ការតាំងសំណួររបស់ភាគីទៅលើសាក្សី:*

ក. ភាគី ពុំត្រូវសួរសំណួរដែលមានលក្ខណៈនាំមុខ នៅក្នុងប្រធានបទដែលមានលក្ខណៈចម្រូងចម្រាស លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះ។

ខ. សំណួររបស់ភាគី គឺត្រូវជាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ដោយរួមបញ្ចូលទាំងភាពអាចជឿទុកចិត្តបាន និងជឿជាក់បាននៃភស្តុតាង។

គ. ភាគី ត្រូវបានរំពឹងថា នឹងប្រើប្រាស់ពេលវេលាដែលផ្ដល់នេះ បានយ៉ាងមានប្រសិទ្ធិភាព ក្នុងន័យនេះ គឺដើម្បីជៀសវាងនូវសំណួរវែង ច្រំដែល ឬគ្មានភាពជាប់ពាក់ព័ន្ធ។ អង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាលើកត្តានេះ រួមជាមួយនឹងពេលវេលាដែលចំណាយលើការជំទាស់ដោយគ្មានមូលដ្ឋានត្រឹមត្រូវ និងការរំខានផ្សេងៗទៀត ក្នុងការសម្រេចលើសំណើសុំពេលវេលាបន្ថែមដែលភាគីនានាអាចស្នើឡើង នៅពេលនោះ។

២. *ការប្រើប្រាស់ចម្លើយពីមុនរបស់សាក្សី:*

លើកលែងតែមានការណែនាំពីអង្គជំនុំជម្រះ ការតាំងសំណួរលើសាក្សី ពុំត្រូវធ្វើឡើងដោយគ្រាន់តែអាននូវអត្ថបទនៃចម្លើយពីមុនរបស់សាក្សីឱ្យគាត់ស្ដាប់ ហើយធ្វើការបញ្ជាក់នោះទេ។ ទោះបីជា

[9] ឧបសម្ព័ន្ធ–កាលវិភាគសម្រាប់សវនាការដែលបានកែប្រែនៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារលេខ F26.1។

យ៉ាងណាក៏ដោយ ចម្លើយពីមុនរបស់សាក្សី អាចត្រូវបានប្រើប្រាស់*ក្នុងនោះ* ដើម្បីល្បងលើភាពអាចជឿជាក់បានរបស់សាក្សី ឬបញ្ជាក់អំពីភាពមិនស្របគ្នារវាងចម្លើយផ្សេងៗ។

៣. *ការជូនដំណឹងអំពីសម្ភារៈ*

ក. ភាគីនីមួយៗ ត្រូវដាក់បញ្ជីសម្ភារៈដែលខ្លួនមានបំណងប្រើប្រាស់នៅក្នុងអំឡុងពេលសួរសាក្សី ត្រឹមថ្ងៃ ពុធ ទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ និងតាមរយៈអ៊ីមែលមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ព្រមទាំងភាគីដទៃទៀត ក្នុងសំណុំរឿង ០០២/០១។ បញ្ជីនៃឯកសារនេះ ត្រូវចងក្រងជាតារាងកម្មវិធី Excel ហើយ ជាអប្បបរមា ត្រូវរួមបញ្ចូលលេខ និងចំណងជើងរបស់ឯកសារនីមួយៗ។ ប្រសិនបើ ឯកសារពុំអាចយកបានពីប្រព័ន្ធផ្ទុកទិន្នន័យរបស់ Zylab ទេនោះ ភាគីតម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារចម្លងដោយម៉ាស៊ីនស្កេនទៅកាន់អ៊ីមែល ដែលបានរៀបរាប់ខាងលើ។ ប្រសិនបើ ឯកសារនេះ ច្រើនជាង ៣០ ទំព័រ ភាគីត្រូវជ្រើសរើសតែផ្នែកណាដែលខ្លួនត្រូវប្រើ ក្នុងពេលសួរសំណួរ ហើយផ្តល់លេខឯកសារនីមួយៗ ប្រសិនបើមាន។ ឯកសារដែលពុំមានជាភាសាខ្មែរ និងអង់គ្លេស ឬបារាំង ពុំត្រូវបានទទួលយកឡើយ។ ទោះក្នុងករណីណាក៏ដោយ ក្នុងអំឡុងពេលសួរសំណួរសាក្សី អង្គជំនុំជម្រះតុលាការកំពូល ពុំអនុញ្ញាតឱ្យប្រើប្រាស់ឯកសារណាមួយ ដែលពុំមាននៅក្នុងបញ្ជីឯកសារឡើយ។

ខ. រាល់ការជំទាស់ណាមួយទៅនឹងឯកសារ ដែលមានបំណងប្រើប្រាស់ ក្នុងអំឡុងពេលសួរសំណួរសាក្សី ត្រូវដាក់ត្រឹមថ្ងៃទី សុក្រ ទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ តាមរយៈប្រព័ន្ធដាក់ឯកសារតាមអេឡិចត្រូនិកធម្មតា។ ទោះក្នុងករណីណាក៏ដោយ ក្នុងអំឡុងពេលសួរសំណួរសាក្សី អង្គជំនុំជម្រះតុលាការកំពូល ពុំពិចារណាទៅលើការជំទាស់ណាមួយទៅនឹងឯកសារ ដែលត្រូវបានលើកឡើងនៅដំណាក់កាលក្រោយមកទៀត រួមទាំងក្នុងអំឡុងពេលសវនាការនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**